# ការជ្រើសរើស

សេចក្តីពិតមួយដែលព្រះគម្ពីរបង្រៀនដែលធ្វើអោយគ្រីស្ទបរិស័ទមានការយល់ច្រឡំជាញឹកញាប់គឺ ការជ្រើសរើស ។ ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់លាស់ថា ព្រះជ្រើសរើសរាស្ត្ររបស់ទ្រង់ ។ ឧទាហរណ៍ ព្រះគម្ពីរបង្រៀននេះអំពីពួកអ៊ីស្រាអែល (ចោទិយកថា ៧:៦-៧; ១០:១៥; ១៤:២; នេហេមា ៩:៧; ទំនុកដំកើង ៣៣:១២; ១០៥:៦) ហើយអំពីគ្រីស្ទបរិស័ទ (ម៉ាថាយ ១១:២៧; ២៤:៣១; ម៉ាកុស ១៣:២០; យ៉ូហាន ១៥:១៦,១៩; រ៉ូម ៩:១១-១៣; ១១:៥; អេភេសូរ ១:៤-៥; ១ថែស្សាឡូនីច ១:៤; ២ថែស្សាឡូនីច ២:១៣; ១ពេត្រុស ១:២; ២:៩)។

ខគម្ពីរទាំងលើនេះគ្រាន់តែជាបទគម្ពីរខ្លះៗដែលបង្រៀនថា ព្រះជ្រើសរើសរាស្ត្ររបស់ទ្រង់ ប៉ុន្តែនៅមានខគម្ពីរដែលបង្រៀនដូចនេះជាច្រើនផ្សេងទៀត។ ទោះយ៉ាងណា មានការព្រងើយកន្តើយចំពោះសេចក្តីពិតនេះយ៉ាងខ្លាំង។ ជារឿយៗ មិនមានអ្នកបង្រៀន អធិប្បាយ ឬសិក្សាអំពីសេចក្តីពិតនេះទេ។ ពេលខ្លះដោយសារយើងគិតថា សេចក្តីពិតនេះមានការពិបាកយល់ណាស់ ឬដោយសារយើងគិតថា សេចក្តីពិតនេះមិនមានលក្ខណៈអនុវត្ត និងមិនសំខាន់ទេ ។ ប៉ុន្តែព្រះបង្រៀនអំពីសេចក្តីពិតនេះដល់រាស្ត្ររបស់ទ្រង់ច្រើនដង ហើយនេះបង្ហាញថា វាគឺជាសេចក្តីពិតសំខាន់មួយ ដែលទ្រង់ចង់អោយយើងដឹងនិងចងចាំ ។

**អ្វីដែលខគម្ពីរទាំងនេះបង្រៀន**

នៅពេលយើងគិតអំពីការជ្រើសរើស មនុស្សខ្លះគិតថា ព្រះគម្ពីរបង្រៀនថា ព្រះបានជ្រើសរើសយើង ដោយទ្រង់ជ្រាបជាមុនថា អ្នកនឹងមានសេចក្តីជំនឿលើព្រះយេស៊ូវ។ យោងតាមទស្សនៈនេះ ព្រះជ្រើសរើសយើងដោយព្រោះយើងមានសេចក្តីជំនឿ គឺថា ព្រះបានជ្រើសរើសយើង ដោយសារអ្វីដែលយើងធ្វើ។ ព្រះបានជ្រើសរើសយើង ដោយព្រោះយើងបានជ្រើសរើសជឿដល់ទ្រង់។ ប៉ុន្តែនេះមិនមែនជាអ្វីដែលខគម្ពីរខាងលើបង្រៀនទេ។ ខគម្ពីរទាំងនោះបង្រៀនយ៉ាងច្បាស់លាស់ថា ព្រះបានជ្រើសរើសយើងមុនការបង្កើតលោកិយមកម្ល៉េះ (អេភេសូរ ១:៤, ១១) ទ្រង់បានជ្រើសរើសយើង មិនមែនយើងបានជ្រើសរើសទ្រង់ទេ (ដូចដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកសិស្សក្នុងយ៉ូហាន ១៥:១៦) ហើយជម្រើសរបស់ព្រះមិនផ្អែកលើសកម្មភាពរបស់យើងទេ ប៉ុន្តែផ្អែកលើជម្រើសដ៏មានអធិបតេយ្យភាពរបស់ទ្រង់វិញ (រ៉ូម ៩:១១-១៦) ។

**ការអនុវត្ត**

មានមូលហេតុខ្លះៗនៅក្នុងព្រះគម្ពីរ ដែលព្រះបន្តបង្រៀនសេចក្តីពិតនេះដល់រាស្ត្ររបស់ទ្រង់ ។

**១. ធ្វើអោយយើងបន្ទាបខ្លួន** ។ ប្រសិនបើព្រះបានជ្រើសរើសយើង ដោយសារការល្អនៅក្នុងខ្លួនរបស់យើង នោះយើងអាចមានអំនួតនៅក្នុងខ្លួនរបស់យើង ។ ប៉ុន្តែ១កូរិនថូស ១:២៦-៣១ បង្រៀនថា ព្រះ**មិន**បានជ្រើសរើសយើងដោយសារតែអ្វីដែលយើងអាចអួតអំពីឡើយ។ ព្រះបង្រៀនសេចក្តីពិតនេះដើម្បីធ្វើអោយ

យើងចេះបន្ទាប់ និងមនុស្សទាំងអស់ចេះបន្ទាបខ្លួនផងដែរ។ ប្រសិនបើខ្ញុំគឺជាម្នាក់នឹងជ្រើសរើសអ្នកដែលនឹងលេងបាល់ទាត់នៅក្នុងក្រុមបាល់ទាត់កម្ពុជា ដើម្បីតំណាងអោយប្រទេសកម្ពុជា នោះបើសិនជាខ្ញុំនឹងជ្រើសរើសកីឡាករម្នាក់អន់មែនទែន ដោយព្រោះខ្ញុំចង់បង្ហាញសេចក្តីសន្តានចិត្តល្អដល់គាត់ ការនេះមិននាំអោយគាត់អាចមានអ្វីអួតបានឡើយ។ ដូចគ្នាដែរ នៅពេលព្រះជ្រើសរើសយើង មិនមានអ្វីដែលយើងអាចអួតបានឡើយ ប៉ុន្តែយើងអួតអំពីព្រះវិញ (១កូរិនថូស ១:៣១) ។  ក៏សំរាប់អ៊ីស្រាអែលផងដែរ ទ្រង់ប្រាប់ពួកគេថា វាមិនដោយសារតែភាពអស្ចារ្យរបស់ពួកគេ ដែលទ្រង់បានជ្រើសរើសពួកគេឡើយ (ចោទិយកថា ៧:៦-៧) ។ ប្រសិនបើយើងគិតថា ព្រះបានជ្រើសរើសយើង ដោយព្រោះអ្វីដែលយើងបានធ្វើ នោះយើងអាចមានអំនួតលើសអ្នកដទៃទៀតដែលមិនមានជំនឿ។ យើងអាចគិតថា យើងល្អជាងពួកគេ។ ព្រះមិនចង់អោយយើងគិតរបៀបនេះឡើយ។ ប្រសិនបើព្រះបានជ្រើសរើស ដោយផ្អែកលើអ្វីដែលយើងបានធ្វើ នោះយើងមិនបានសង្គ្រោះដោយសារព្រះគុណនោះឡើយ។  ប៉ុន្តែយើងពិតជាបានសង្គ្រោះដោយសារព្រះគុណមែន អញ្ចឹងវាត្រូវតែជាជម្រើសរបស់ទ្រង់ផ្ទាល់។ ហើយដោយសារព្រះគុណដែលព្រះបានជ្រើសរើសយើង នោះយើងមិនមានអ្វីអួតអំពីឡើយ។

**២. លើកទឹកចិត្តនិងកំសាន្តចិត្តរាស្ត្ររបស់ទ្រង់** ។ រាស្ត្ររបស់ទ្រង់អាចជួបស្ថានភាពលំបាកនៅក្នុងលោកិយនេះ ហើយពេលខ្លះ ពួកគេប្រហែលជាសង្ស័យថា ព្រះបានបដិសេធពួកគេ ឬឈប់ស្រលាញ់ពួកគេទៀតហើយ។ ពេញក្នុងប្រវត្តិសាស្ត្រ នៅពេលរាស្ត្ររបស់ព្រះបានសង្ស័យលើព្រះ ទ្រង់រំលឹកពួកគេតាមរយៈព្រះបន្ទូលថា ទ្រង់បានជ្រើសរើសពួកគេ ក្នុងគោលបំណងលើកទឹកចិត្តពួកគេ (ឧ. សំរាប់អ៊ីស្រាអែល អេសាយ ៤១:៨-៩ សំរាប់គ្រីស្ទបរិស័ទ រ៉ូម ៨:២៨-៣៩)។ ការចង់ចាំថា ទ្រង់បានជ្រើសរើសយើង ជួយអោយយើងយល់ថា យើងគឺជាកម្មសិទ្ធិរបស់ទ្រង់ យើងជារបស់ទ្រង់ ហើយទ្រង់នឹងថែរក្សាយើង។  នេះមិនមានន័យថា យើងនឹងមិនមានបញ្ហានៅក្នុងជីវិតនោះទេ ប៉ុន្តែជីវិតអស់កល្បជានិច្ចរបស់យើងមានការធានា ពីព្រោះទ្រង់បានជ្រើសរើសយើងនៅក្នុងព្រះគ្រីស្ទ។

**៣. លើកទឹកចិត្តយើងអោយបំរើព្រះ និងមានជីវិតបរិសុទ្ធ** ។ ព្រះបានជ្រើសរើសអ៊ីស្រាអែលអោយបានបរិសុទ្ធសំរាប់ទ្រង់ (ចោទិយកថា ៧:៦) ហើយក៏ដូចគ្នាសំរាប់គ្រីស្ទបរិស័ទនៅក្នុងសម្ព័ន្ធមេត្រីថ្មីផងដែរ។ ជាឧទាហរណ៍ អេភេសូរ ១:៤ សរសេរថា «តាមដែលទ្រង់បានរើសយើង រាល់គ្នាក្នុងព្រះគ្រីស្ទ តាំងពីមុនកំណើតលោកីយ៍មកប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ» (សូមមើលយ៉ូហាន ១៥:១៩ ផងដែរ)។ ប្រសិនបើខ្ញុំជាអ្នកជ្រើសរើសមនុស្សលេងបាល់ទាត់នៅក្នុងក្រុមបាល់ទាត់កម្ពុជា ដើម្បីតំណាងអោយប្រទេសកម្ពុជា នោះបើសិនជាខ្ញុំជ្រើសរើសកីឡាករម្នាក់ បន្ទាប់មកកីឡាករនោះគួរតែលេងបាល់ទាត់សំរាប់កម្ពុជា។ នោះគឺជាអ្វីដែលគាត់ត្រូវបានខ្ញុំជ្រើសរើសអោយធ្វើ។ វាជាការខុសប្រសិនបើក្រុមបាល់ទាត់កម្ពុជាបានមានការប្រកួតមួយជាមួយប្រទេសមួយទៀត ហើយកីឡាករដែលខ្ញុំបានជ្រើសរើសនោះបែរជាទៅស្ទូចត្រីវិញនោះ។ ដូចគ្នាដែរ ប្រសិនបើព្រះបានជ្រើសរើសយើងអោយបានបរិសុទ្ធ នោះហើយជាអ្វីដែលយើងគួរតែធ្វើ។

ការចងចាំថា យើងមានពរដោយសារទ្រង់បានជ្រើសរើសយើង (ទំនុកដំកើង ៣៣:១២) លើកទឹកចិត្តយើងអោយចេះអរព្រះគុណ និងបំរើទ្រង់។ ការចងចាំថា ទ្រង់បានជ្រើសរើសយើងជួយយើងអោយយល់ថា យើងជាកម្មសិទ្ធិរបស់ទ្រង់ យើងជារបស់ទ្រង់ ដូច្នេះយើងគួរតែបំរើទ្រង់។ ដូច្នេះ នេះគឺជាសេចក្តីពិតមួយដ៏សំខាន់សំរាប់អស់អ្នកជឿនៅក្នុងព្រះគ្រីស្ទអោយរំលឹកខ្លួនឯងជារៀងរាល់ព្រឹក។ ជារៀងរាល់ព្រឹក ប្រាប់ខ្លួនឯងយើងថា ព្រះបានជ្រើសរើសខ្ញុំ ដូច្នេះ ខ្ញុំជារបស់ទ្រង់ ខ្ញុំគួរតែបរិសុទ្ធ ហើយខ្ញុំគួរតែបំរើព្រះនៅថ្ងៃនេះ ដោយអរព្រះគុណ។

**៤. បែងចែកអស់អ្នកដែលពិតជារាស្ត្ររបស់ទ្រង់ ។** មានមនុស្សជាច្រើនដែលអះអាងថាគេស្គាល់ព្រះយេស៊ូវ ប៉ុន្តែនៅថ្ងៃចុងក្រោយ ព្រះយេស៊ូវនឹងបើកសំដែងថា ទ្រង់មិនស្គាល់ពួកគេ ហើយទ្រង់នឹងបដិសេធពួកគេ (ម៉ាថាយ ៧:២១-៣៣) ។ ប៉ុន្តែ អស់អ្នកដែលជា «អ្នកជ្រើសតាំង» នឹងបានជួបជុំគ្នាជាមួយព្រះយេស៊ូវ (ម៉ាកុស ១៣:២៧; រ៉ូម ១១:៧) ។

ដូច្នេះ យើងឃើញថា នេះគឺជាសេចក្តីពិតសំខាន់មួយសំរាប់គ្រីស្ទបរិស័ទគ្រប់រូបរៀន ចងចាំ និងអនុវត្តនៅក្នុងជីវិត។ ចូរបន្ទាបខ្លួន និងទទួលការលើកទឹកចិត្តដោយសេចក្តីពិតដែលថា ព្រះបានជ្រើសរើសយើងនៅក្នុងព្រះគ្រីស្ទ ហើយបានលើកទឹកចិត្តយើងអោយបំរើទ្រង់ដោយទឹកចិត្តអរព្រះគុណ។